

# ល្បែងដូមីណូអំពីឧបករណ៍ការងារ

សកម្មភាព ៖

ចិត្តចលភាព ៖ បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)

វិទ្យាសាស្ត្រ ៖ បំណិនក្នុងសង្គម(ចំណេះដឹងអំពីរសហគមន៍)

បុរេគណិត ៖ ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ) រូបរាង និងលំហ (បញ្ញត្តិនៃរូបរាង និងលំហ)

គោលបំណង ៖

(ចិត្តចលភាព)៖ ប្រាប់ពីរបៀបធ្វើចលនាតាមបែបទម្រង់ផ្សេងៗ ដោយការធ្វើអ្វីមួយ ឬ ការលេងល្បែងផ្សេងៗ។

(វិទ្យាសាស្ត្រ) ៖ ប្រាប់បានពីឈ្មោះឧបករណ៍តាមមុខរបរ។

(បុរេគណិត) ៖ ប្រាប់បានពីការរៀបតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌ប្រាប់បានពីរបៀបរៀបតាមចង្វាក់ដដែលៗ នូវរូបរាងធរណីមាត្រតាមពណ៌បន្តគ្នា និងតាមលំដាប់លំដោយ ។ កំណត់ទីតាំងវត្ថុមួយផ្សេងទៀតដោយប្រើពាក្យ ខាងលើ ខាងក្រោម

ខាងមុខ ខាងក្រោយ ខាងឆ្វេង ខាងស្តាំ ខាងក្នុង ខាងក្រៅ។

កម្រិតសិក្សា ៖ ទាប មធ្យម ខ្ពស់

សៀវភៅ ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី?"

រយៈពេល ៖ ៣០ នាទី

ឧបករណ៍ ៖ ក្រដាសដូមីណូ (ខ្មៅស, ពណ៌)

សេក្តីណែនាំ ៖

១.ផ្កាប់កាតដូមីណូ ហើយច្របល់។

២.ចែកកាតដូមីណូឱ្យក្មេងតាមក្រុមម្នាក់ ៤សន្លឹក។

៣.កាតដូមីណូរូបឧបករណ៍ការងារផ្សេងដែលនៅសល់ត្រូវដាក់នៅចំកណ្តាល។

៤.ប្រាប់ឱ្យក្មេងណាម្នាក់ចាប់ផ្តើមលេង ដោយដាក់កាតដូមីណូផ្ងាមួយសន្លឹកនៅចំកណ្តាល។

៥.ឬត្រូវប៉ាវ ដើម្បីរកអ្នកឈ្នះ និងចាប់ផ្តើមលេងមុន។

៦.បន្ទាប់មកក្មេងដែលនៅបន្ទាប់ខាងស្តាំដៃ ត្រូវដាក់ដូមីណូរូបឧបករណ៍ រូបដូចគ្នាផ្ទាបន្តគ្នា ដូចក្មេងទី ១បានដាក់នោះដែរ (ឧទាហរណ៍៖រូបញញួរបន្តញញួរត្រូវនៅបន្តបន្ទាប់គ្នា)។

៧.ប្រសិនបើកាតក្មេងបន្ទាប់មិនមានដូចទៅនឹងកាតផ្ទាបន្តគ្នាមុនទេនោះ ត្រូវហូតកាតដូមីណូដែលនៅកណ្តាល១សន្លឹក មកមើលថាមានរូបភាពដូចដែរគ្នាដែរឬទេ។ បើដូចអាចដាក់តគ្នាបាន តែបើមិនដូចទេត្រូវរក្សាទុកកាតហ្នឹងសិន ឱ្យវេនទៅក្មេងបន្ទាប់ទៀត។

៨.បន្ទាប់មក ប្រាប់ឱ្យក្មេងបន្ទាប់ទៀត ដាក់តកាតដូមីណូរូបឧបករណ៍ការងារដូចគ្នានឹងខាងលើដែរ។

៩.ក្មេងទាំងអស់ត្រូវដាក់កាតដូមីណូរបស់ខ្លួន ឬ ហូតកាតដូមីណូដែលចំកណ្តាលនោះម្នាក់ម្តងៗតាមលំដាប់លំដោយ។

១០.ធ្វើបែបហ្នឹងរហូតដល់ក្មេងៗណាដែលអស់កាតដូមីណូរូបឧបករណ៍នៅក្នុងដៃក្មេងម្នាក់នោះគឺជាអ្នកឈ្នះតែម្តង។

១១.ហើយប្រសិនបើកាតដែលនៅចំកណ្តាលអស់ហើយ ក្មេងនៅតែសល់កាតដែលមិនទាន់បានដាក់អស់នោះ អ្នកត្រូវកំណត់ថាក្មេងម្នាក់ណាដែលនៅសល់កាតតិចជាងគេ នោះគឺជាអ្នកឈ្នះបានតែម្តង។